**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៦.១៣-០១៨-៤៥៣ ន.ស.ស.ក

ថ្ងៃ អង្គារ ៩ រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ លើកទី៤២

នៅថ្ងៃសុក្រ ៦ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ៨:៣០ នាទីព្រឹក ធនាគារជាតិនៃកម្ពុជា បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការ-គោលនយោបាយរូបិយវត្ថុ លើកទី៤២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ទេសាភិបាល និងជាប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ។ អង្គប្រជុំបានពិភាក្សាលើរបាយការណ៍ ស្តីពី ស្ថានភាពអតិផរណាប្រចាំត្រីមាសទី៤ ឆ្នាំ២០១៧ និងបានសម្រេចលើជម្រើសការអនុវត្តគោលនយោបាយរូបិយវត្ថុចម្បងៗសម្រាប់ឆ្នាំ២០១៨ ដូចខាងក្រោម ៖

១-/ បន្តប្រកាន់យករបបអត្រាប្តូរប្រាក់ស្ថិរភាព ដោយធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់ស្របតាមស្ថានភាពរីកចម្រើននៃសេដ្ឋកិច្ច និងកំណើនតម្រូវការប្រាក់រៀល

២/- បន្តអភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុ ផ្អែកលើយន្តការទីផ្សារ ជាពិសេសមូលបត្រអាចជួញដូរបាន (NCD) និង ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដើម្បីគ្រប់គ្រងសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ និងលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ និង

៣/- បញ្ឈប់ការផ្តល់ការប្រាក់លើប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ។

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ**

**ជា-ចាន់តូ**

**ចម្លងជូន ៖**
- សមាជិកគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ
- ឯកសារ-កាលប្បវត្តិ

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧